# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ

**សាលាដំបូង ខេត្តកំពង់ធំ**

**សាលក្រមរដ្ឋប្បវេណីលេខ : ០៣ "ង"**

**ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០២០**

**-បានឃើញច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខៈ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ។**

**-សំណុំរឿងរដ្ឋប្បវេណីលេខ : ៣៧២/០១ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៨ ។**

**-កម្មវត្ថុបណ្តឹង :** ប្តឹងទាមទារប្រាក់ចំនួន ៥៨,000 ដុល្លារអាមេរិក (ប្រាំម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) និង មាសចំនួន ៣៨តំឡឹង (សាបសិបប្រាំបីតំឡឹង) ។

**-ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និង ថ្ងៃប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០២០ ។**

**សាលាដំបូងខេត្តកំពង់ធំ ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ :**

**-លោក [redacted] ជាចៅក្រមទទួលបន្ទុក**

**-កញ្ញា [redacted] ជាក្រឡាបញ្ជី**

**-ដើមចោទឈ្មោះ [redacted] គឹមធី ភេទស្រី អាយុ៥១ឆ្នាំ** ទីលំនៅសព្វថ្ងៃ [redacted] ។

**-សហចុងចម្លើយ**

**ក-ឈ្មោះ [redacted] គឹមអាត ឬ [redacted] គឹមអាត ភេទស្រី អាយុ៤៦ឆ្នាំ** ទីលំនៅសព្វថ្ងៃ [redacted] ។

**មេធាវីតំណាងដោយអាណត្តិលោកស្រី [redacted] អត្តលេខ : ២០១៧ T** មានអាសយដ្ឋានស្ថិតនៅ [redacted] ។

**ខ-ឈ្មោះ** [redacted] **ហ៊ុយ ឬ** [redacted] **សុខឃឿន ភេទប្រុស អាយុ៥១ឆ្នាំ** ទីលំនៅសព្វថ្ងៃ [redacted] ។

**មេធាវីតំណាងដោយអាណត្តិលោក** [redacted] **អត្តលេខ : ១៥៤៩** ដែលមានអាសយដ្ឋាន [redacted] ។

## អង្គហេតុ និង ចំណុចវិវាទ

### ១-សាលក្រមដែលទាមទារ ដោយដើមចោទ

**ក**-ទាមទារប្រាក់ដើមនៅជិពាក់ចំនួន ៥៨,000 ដុល្លារអាមេរិក (ប្រាំម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក ) និង មាសចំនួន ៣៨តំឡឹង (សាបសិបប្រាំបីតំឡឹង) ។

**ខ**-ទាមទារការប្រាក់ចំនួន ១ ភាគរយ ក្នុងមួយខែ រហូតសងគ្រប់ ។

**គ**-ទាមទារសំណងជម្ងឺចិត្ត និង សេវាចំណាយផ្សេងៗ ចំនួន ១00,000ដុល្លារអាមេរិក (ដប់ម៉ឺនដុល្លារ អាមេរិក) ។

**ឃ**-សុំសាលក្រមប្រកាសមានប្រសិទ្ធិភាពអនុវត្តជាបណ្តោះអាសន្នបាន ។

**ង**-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

### ២-ការពន្យល់ត្រួសៗអំពីរឿងក្តី

កាលពីថ្ងៃទី ០១-មករា-១៩៩៩ សហចុងចម្លើយឈ្មោះ [redacted] គីមអាត ភេទស្រី និង ឈ្មោះ [redacted] ហ៊ុយ ឬ [redacted] សុខឃឿន (អតីតប្តី ប្រពន្ធ) បានខ្ចីប្រាក់ពីដើមឈ្មោះ [redacted] គីមធី ភេទស្រី ចំនួន ៣0,000ដុល្លារអាមេរិក (បីម៉ឺនដុល្លារអាមេរិក) និង មាសគីឡូចំនួន ២0តំឡឹង (ម្ភៃតំឡឹង) ដោយកំណត់រយៈពេលខ្ចីចំនួន0៥ឆ្នាំ គឺថ្ងៃកំណត់សងនៅថ្ងៃទី ០១-មករា-២00៤ ។

បន្ទាប់នៅថ្ងៃទី ៣0-មេសា-២000 សហចុងចម្លើយទាំងពីរនាក់បានទៅខ្ចីប្រាក់ និង មាស ពីដើមចោទបន្ថែមទៀត ដោយខ្ចីប្រាក់បន្ថែមចំនួន ៨,000ដុល្លារអាមេរិក (ប្រាំបីពាន់ដុល្លារអាមេរិក) និង មាសគីឡូចំនួន ១៨តំឡឹង (ដប់ប្រាំបីតំឡឹង) ដោយកំណត់រយៈខ្ចីចំនួន0៣ឆ្នាំ គឺថ្ងៃកំណត់សងនៅថ្ងៃទី ៣0-ធ្នូ-២00៣ ។

និងនៅលើកទី៣ មិនចាំថ្ងៃ ខែ ឆ្នាំ សហចុងចម្លើយបានមកខ្ចីប្រាក់បន្ថែមចំនួន ២0,000ដុល្លារអាមេរិក (ពីរម៉ឺនដុល្លារអាមេរិក) តែមិនបានធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ទេ គឺមកខ្ចីដោយផ្ទាល់មាត់ ។

ក្នុងការខ្ចីប្រាក់ និង មាសនេះ គូភាគីបានព្រមព្រៀងគ្នាបង់ការប្រាក់ចំនួន ១ភាគរយក្នុងមួយខែ ដោយចុងចម្លើយបង់ការប្រាក់ឱ្យទៅដើមចោទប្រាក់ដុល្លារចំនួន ៥៨0ដុល្លារអាមេរិក និងមាសចំនួន ៣ជី0៨ហ៊ុន ហើយ

ការប្រាក់នេះចុងចម្លើយបានបង់ឱ្យដើមចោទចាប់ពីពេលខ្ចីរហូតដល់កំឡុងខែ កក្កដា ឆ្នាំ ២០១៦ ទើបចុងចម្លើយឈប់បង់ការប្រាក់ឱ្យទៅដើមចោទ ។

## ៣–អង្គហេតុដែលមានវិវាទ

ចុងចម្លើយឈ្មោះ [redacted] ហ៊ុយ បដិសេធមិនទទួលស្គាល់បំណុល ។

## ៤–អង្គហេតុដែលគ្មានវិវាទ

ចុងចម្លើយឈ្មោះ [redacted] គឹមអាត ឬ [redacted] គឹមអាត ដែលមានមេធាវីតំណាងដោយអាណត្តិលោកស្រី [redacted] ទទួលស្គាល់ថា កូនក្តីរបស់ខ្លួនពិតជាបានជំពាក់ប្រាក់ដើមចោទ ចំនួន ៥៨,000ដុល្លារអាមេរិក និង មាស ចំនួន ៣៨តំឡឹង ។

## ៥–សេចក្តីថ្លែងការណ៍របស់គូភាគី

**ក–ដើមចោទឈ្មោះ [redacted] គឹមធី បានធ្វើសេចក្តីថ្លែងការណ៍ថា** ៖ កាលពីថ្ងៃទី ០១–មករា–១៩៩៩ ចុងចម្លើយឈ្មោះ [redacted] គឹមអាត ភេទស្រី និង ឈ្មោះ [redacted] ហ៊ុយ ឬ [redacted] សុខឃឿន (អតីតប្តី ប្រពន្ធ) បានខ្ចីប្រាក់ពីខ្លួនចំនួនបីលើក លើកទី១មានចំនួន ៣០,000ដុល្លារអាមេរិក (បីម៉ឺនដុល្លារអាមេរិក) និង មាសគីឡូចំនួន ២០តំឡឹង (ម្ភៃតំឡឹង) ដោយកំណត់រយៈពេលខ្ចីចំនួន០៥ឆ្នាំ គឺថ្ងៃកំណត់សងនៅថ្ងៃទី ០១–មករា–២00៤ ។

លើកទី២នៅថ្ងៃទី ៣0–មេសា–២000 ចុងចម្លើយបានមកខ្ចីប្រាក់ និង មាស ពីខ្លួនបន្ថែមទៀត ដោយខ្ចីប្រាក់បន្ថែមចំនួន ៨,000ដុល្លារអាមេរិក (ប្រាំបីពាន់ដុល្លារអាមេរិក) និង មាសគីឡូចំនួន ១៨តំឡឹង (ដប់ប្រាំបីតំឡឹង) ដោយកំណត់រយៈខ្ចីចំនួន០៣ឆ្នាំ គឺថ្ងៃកំណត់សងនៅថ្ងៃទី ៣0–ធ្នូ–២00៣ ។

ក្នុងការខ្ចីប្រាក់ និង មាស ទាំងពីលើកនេះ ចុងចម្លើយបានធ្វើកិច្ចសន្យាដាក់បញ្ចាំ ខ្ចី ចងការប្រាក់ និង លិខិតខ្ចីប្រាក់ ចុះថ្ងៃទី ០១–មករា–១៩៩៩ ដោយបានដាក់បញ្ចាំ ដី និង ផ្ទះ ដែលមានបណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ H1 ១៦០ ចុះថ្ងៃទី ២៨–កញ្ញា–១៩៩៣ ។ ក្រោយមកចុងចម្លើយឈ្មោះ [redacted] គឹមអាត បានមកសុំប្តូរដី និង ផ្ទះនេះយកទៅបញ្ចាំនៅធនាគារ ដើម្បីយកប្រាក់មកសងខ្លួន តែនៅពេលចុងចម្លើយបានខ្ចីប្រាក់ពីធនាគារហើយ មិនបានយកប្រាក់មកសងខ្លួននោះទេ ។

និងនៅលើកទី៣ មិនចាំថ្ងៃ ខែ ឆ្នាំ សហចុងចម្លើយបានមកខ្ចីប្រាក់បន្ថែមចំនួន ២0,000ដុល្លារអាមេរិក (ពីរម៉ឺនដុល្លារអាមេរិក) តែមិនបានធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរទេ គឺមកខ្ចីដោយផ្ទាល់មាត់ ដោយចុងចម្លើយឈ្មោះ [redacted] គឹមអាត មកខ្ចីប្រាក់នេះ ដើម្បីទៅប្រទេសចិនទៅទិញទំនិញយកមកលក់ ។

ការខ្ចីប្រាក់នេះគឺចុងចម្លើយទាំងពីរនាក់នៅរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធនៅឡើយទេ មិនទាន់ឈ្លោះបែកបាក់គ្នាទេ ។

ក្នុងការខ្ចីប្រាក់ និង មាសនេះ ចុងចម្លើយទាំងពីរនាក់បានព្រមព្រៀងគ្នាបង់ការប្រាក់ឱ្យមកខ្លួនចំនួន ១ភាគរយក្នុងមួយខែ ដោយចុងចម្លើយបង់ការប្រាក់ជាប្រាក់ដុល្លារចំនួន ៥៨០ដុល្លារអាមេរិក និង មាសចំនួន ៣ជី០៨ហ៊ុន ឱ្យមកខ្លួនក្នុងមួយខែ ហើយការបង់ការប្រាក់នេះចុងចម្លើយបានបង់ឱ្យមកខ្លួនចាប់ពីពេលខ្ចីរហូតមក មិនដែលខកខានមួយខែណាឡើយ រហូតដល់កំឡុង ខែ កក្កដា ឆ្នាំ ២០១៦ ទើបចុងចម្លើយឈប់បង់ការប្រាក់ឱ្យមកខ្លួន ដោយមូលហេតុថា ចុងចម្លើយទាំងពីរនាក់បានឈ្លោះបែកបាក់គ្នាជាប្តី ប្រពន្ធ ក៏ខ្លួនដាក់ពាក្យបណ្តឹងមកតុលាការតែម្តង ។

ចំពោះប្រាក់ប្រដាប់ក្តីខ្លួនសុំអោយចុងចម្លើយទាំងពីរនាក់ជាអ្នកទទួលបន្ទុកលើប្រាក់ប្រដាប់ក្តីនេះ ។

ខ្លួនសំណូមពរសុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម :

–ទាមទារប្រាក់ដើមនៅជំពាក់ចំនួន ៥៨,000 ដុល្លារអាមេរិក (ប្រាំម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក ) និង មាសចំនួន ៣៨តម្លឹង (សាបសិបប្រាំបីតម្លឹង) ។

–ទាមទារការប្រាក់ចំនួន ១ ភាគរយ ក្នុងមួយខែ រហូតសងគ្រប់ ។

–ទាមទារសំណងជម្ងឺចិត្ត និង សេវាចំណាយផ្សេង ចំនួន ១00,000ដុល្លារអាមេរិក (ដប់ម៉ឺនដុល្លារអាមេរិក) ។

–សុំសាលក្រមប្រកាសមានប្រសិទ្ធិភាពអនុវត្តជាបណ្តោះអាសន្នបាន ។

–ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

**ខ–លោកស្រីមេធាវី [redacted] តំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] គឺមរកត បានថ្លែងការណ៍ថា :** ចំពោះបំណុលដែលដើមចោទបានទាមទារមកលើកូនក្តីរបស់ខ្លួននេះ គឺខ្លួនមិនបដិសេធទេ ខ្លួនទទួលស្គាល់តាមការទាមទាររបស់ដើមចោទ ដោយកូនក្តីរបស់ខ្លួនពិតបានជំពាក់ប្រាក់ដើមចោទចំនួន ៥៨,000ដុល្លារអាមេរិក (ប្រាំម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) និង មាសគីឡូចំនួន ៣៨តំឡឹង (សាមសិបប្រាំបីតំឡឹង) ពិតមែន ។ តែបំណុលនេះជំពាក់តាំងពីកូនក្តីរបស់ខ្លួននៅរួមរស់ជាមួយឈ្មោះ [redacted] ហ៊ុយ ជាប្តីប្រពន្ធនឹងគ្នា ហើយក្រោយមានសាលក្រមរបស់សាលាដំបូងខេត្តកំពង់ធំ បានសម្រេចឱ្យកូនក្តីរបស់ខ្លួនលែងលះគ្នា សម្រេចចែងទ្រព្យសម្បត្តិរួម និង បំណុលរួមគ្នា ហើយបន្ទាប់មកឈ្មោះ [redacted] ហ៊ុយ បានប្តឹងឧទ្ធរណ៍នឹងសាលក្រមរបស់សាលាដំបូងខេត្តកំពង់ធំ ទៅសាលាឧទ្ធរណ៍ រួចសាលាឧទ្ធរណ៍បានតំកល់សាលក្រមសាលាដំបូង ទុកជាបានការ ហើយឈ្មោះ [redacted] ហ៊ុយ មិនសុខចិត្តបានសារទុកទៅតុលាការកំពូល រហូតដល់តុលាការតុលាការគឺតុលាការកំពូលបានតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ។

ដូច្នេះខ្លួនមិនបដិសេធនូវការទាមទាររបស់ដើមចោទទេ តែបំណុលនេះគឺជាបំណុលរួម ខ្លួនស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីរបស់ខ្លួន និង ចុងចម្លើយឈ្មោះ [redacted] ហ៊ុយ ទទួលសងរួមគ្នាដែរ ។

គ-ចុងចម្លើយឈ្មោះ [redacted] ហ៊ុយ ឬ [redacted] សុខឃឿន ជាមេធាវីតំណាងដោយអាណត្តិ បានទទួលកាលបរិច្ឆេទ ការទាញហេតុផលដោយផ្ទាល់មាត់រួចហើយ តែនៅថ្ងៃធ្វើការទាញហេតុផលដោយផ្ទាល់មាត់អវត្តមានដោយគ្មានមូលហេតុ ។

**នៅនីតិវិធីត្រៀមសំរាប់ការទាញហេតុផល នៅថ្ងៃទី ០៨-តុលា-២០២០ វេលាម៉ោង ៩.០០នាទី ព្រឹក ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា :** ខ្លួនមិនទទួលស្គាល់តាមការទាមទាររបស់ដើមចោទទេ គឺកាលខ្លួននៅរួមរស់ជាឈ្មោះ [redacted] គឹមអាត ជាប្តីប្រពន្ធ ពួកខ្លួនទាំងពីរនាក់ពិតជាបានខ្ចីមាសពីដើមចោទចំនួន ១៨តំឡឹង ឯប្រាក់ដុល្លារមិនមានទេ ។ ចំពោះមាសចំនួន១៨តំឡឹង ខ្លួនបានឱ្យអតីតប្រពន្ធរបស់ខ្លួនយកមាសចំនួន ១៨តំឡឹង ទៅសងដើមចោទរួចអស់ហើយ ខ្លួនតែខ្លួនមិនបានចាំថ្ងៃ ខែ ឆ្នាំ ទេ ។

ដូច្នេះខ្លួនសុំបដិសេធចោលការទាមទាររបស់ដើមចោទចោលទាំងអស់ ។

**៦-ការពិនិត្យភស្តុតាងមាន :**

-ពាក្យបណ្តឹងចុះថ្ងៃទី ១០-តុលា-២០១៨ ។

-កិច្ចសន្យាដាក់បញ្ចាំ ខ្ចី ចងការ ប្រាក់ និង លិខិតខ្ចីប្រាក់ ចុះថ្ងៃទី ០១-មករា-១៩៩៩ ។

-សាលក្រមរបស់សាលាដំបូងខេត្តកំពង់ធំលេខ : ១៥ "គ" ចុះថ្ងៃទី ១៧-ឧសភា-២០១៧ ។

-សាលដីការបស់សាលាឧទ្ធរណ៍លេខ : ១២ ក្រVII (ធ) ចុះថ្ងៃទី ២៧-មេសា-២០១៨ ។

-សាលដីការបស់តុលាការកំពូលលេខ : ៤៣ "ខ" ចុះថ្ងៃទី ២៦-កុម្ភៈ-២០១៩ ។

## សំអាងហេតុ

**១**-បណ្តឹងទាមទាររបស់ដើមចោទចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៨ ធ្វើឡើងត្រឹមត្រូវតាមនីតិវិធីច្បាប់ ហើយសាលាដំបូងខេត្តកំពង់ធំទទួលមកជំនុំជម្រះបាន ដោយយោងតាមមាត្រា ៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**២**-ការទាញហេតុផលដោយផ្ទាល់មាត់គូភាគីបានថ្លែងការណ៍ដូចខាងក្រោម :

**ក**-ដើមចោទបានធ្វើការបញ្ជាក់ថា ចុងចម្លើយទាំងពីរនាក់ពិតជាបានខ្ចីប្រាក់ពីខ្លួនចំនួន០៣លើក សរុបមានចំនួន ៥៨,០០០ដុល្លារអាមេរិក (ប្រាំម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) និង មាសគីឡូ ចំនួន ៣៨ តំឡឹង (សាបសិបប្រាំបីតំឡឹង) ហើយចុងចម្លើយបានបង់ការប្រាក់ចំនួន០១ភាគរយក្នុងមួយខែរហូតមក ទើបមកដល់កំឡុងខែកក្កដា ឆ្នាំ ២០១៦ ដែលចុងចម្លើយទាំងពីរនាក់បានឈ្លោះបែកបាក់គ្នាក៏ឈប់បង់ការប្រាក់ឱ្យមកខ្លួនតែម្តង ។

**ខ**-លោកស្រី [redacted] មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយឈ្មោះ [redacted] គឹមអាត បានធ្វើការបញ្ជាក់ថា កូនក្តីរបស់ខ្លួនពិតជាបានជំពាក់ប្រាក់ និង មាស ដើមចោទដូចការ



Scanned with CamScanner

ទាមទាររបស់ដើមចោទពិតមែន តែការខ្ចីប្រាក់ និង មាស នេះ គឺខ្ចីតាំងពីកូនក្ដីរបស់ខ្លួននៅរួមរស់ជាប្ដីប្រពន្ធនឹងគ្នា ជាមួយឈ្មោះ [redacted] ហ៊ុយ ដូច្នេះការទទួលខុសត្រូវលើបំណុលត្រូវសងរួមគ្នាដែរ ។

គ–នៅនីតិវិធីត្រៀមសំរាប់ការទាញហេតុផល លោកធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ និង ចុងចម្លើយឈ្មោះ [redacted] ហ៊ុយ បានធ្វើការទទួលស្គាល់ថា ខ្លួន និង អតីតប្រពន្ធរបស់ខ្លួនពិតជាបានខ្ចីមាស ចំនួន១៨តំឡឹង ពីដើមចោទពិតមែន ហើយក្រោយមកមាសចំនួន១៨តំឡឹងនេះ ខ្លួនបានឱ្យឈ្មោះ [redacted] គីមអាត យកទៅសងដើមចោទរួចហើយ ចំពោះចំនួន ៥៨,០០០ដុល្លារអាមេរិក ខ្លួនមិនទទួលស្គាល់ទេ ។

៣–តុលាការកំណត់កាលបរិច្ឆេទនៃ ការទាញហេតុផលដោយផ្ទាល់មាត់ដល់ភាគីចុងចម្លើយឈ្មោះ [redacted] ហ៊ុយ និង មេធាវីតំណាងដោយអាណត្តិបានដឹងរួចហើយ តែដល់ថ្ងៃកំណត់អវត្តមានដោយគ្មានមូលហេតុ ។

យោងតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី អំពីសាលក្រមកំបាំងមុខចុងចម្លើយ

កឋាខណ្ឌទី២ ចែងថា បើចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវចាត់ទុកថា ចុងចម្លើយបានសារភាពតាមសេចក្ដីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុ ហើយបើយល់ឃើញថា ការទាមទាររបស់ដើមចោទត្រឹមត្រូវតុលាការត្រូវទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយសាលក្រមកំបាំងមុខ តែបើយល់ឃើញថា ការទាមទាមរបស់ដើមចោទមិនត្រូវទេ តុលាការត្រូវប្រានចោលការទាមទារនោះ ។

៤–ភស្តុតាងដែលលោកស្រីមេធាវី តំណាងដោយអាណត្តិឱ្យភាគីចុងចម្លើយឈ្មោះ [redacted] គីមអាត បានដាក់ជូនតុលាការពិនិត្យ អំពីការទទួលខុសត្រូវនូវបំណុលរួម ដោយផ្អែកទៅលើសាលក្រមសាលាដំបូងខេត្តកំពង់ធំ សាលដីការបស់សាលាឧទ្ធរណ៍ និង សាលដីការបស់តុលាការកំពូល ដែលមានដូចខាងក្រោម :

–តាមសាលក្រមសាលាដំបូងខេត្តកំពង់ធំលេខ : ១៥ "គ" ចុះថ្ងៃទី ១៧–ឧសភា–២០១៧ ដែលមាន ដើមចោទឈ្មោះ [redacted] គីមអាត ភេទស្រី អាយុ៤៦ឆ្នាំ និង ចុងចម្លើយឈ្មោះ [redacted] ហ៊ុយ ភេទប្រុស អាយុ៥២ឆ្នាំ ។

សេចក្ដីសម្រេចបញ្ចប់ នៃសាលក្រម ចំណុចទី៤ បានសម្រេចអោយភាគីដើមចោទ និង ចុងចម្លើយ រួមគ្នាសងបំណុលដែលជំពាក់ម្ចាស់បំណុលផ្សេងៗ ក្នុងអំឡុងពេលរស់នៅជាអនីតិសង្វាស ។

–តាមសាលដីការបស់សាលាឧទ្ធរណ៍លេខ : ១២ ក្រVII (ធ) ចុះថ្ងៃទី ២៧–មេសា–២០១៨ សេចក្ដីសម្រេចបញ្ចប់នៃសាលដីកា ចំណុចទី១ ច្រាលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៩–មិថុនា–២០១៧ របស់ឈ្មោះ [redacted] ហ៊ុយ ចោល ។ ចំណុចទី២ តម្កល់ចំណុចទី២ ត្រេទី ៣,៤,៧,៨,៩,១០,១១ និង ចំណុចទី៤ នៃសម្រេចរបស់សាលក្រមរដ្ឋប្បវេណីលេខ : ១៥ "គ" ចុះថ្ងៃទី ១៧–មិថុនា–២០១៧ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការដដែល ។



Scanned with CamScanner

-តាមសាលដីការបស់តុលាការកំពូលលេខ ៖ ៤៣ "ខ" ចុះថ្ងៃទី ២៦-កុម្ភៈ-២០១៩ ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី ចំណុចទី១ បដិសេធបណ្តឹងសាទុកលេខ ១៥៩ ចុះថ្ងៃទី ៣១-ឧសភា-២០១៨ របស់លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ [redacted] ហ៊ុយ ។ ចំណុចទី២ តម្កល់សាដីការដ្ឋប្បវេណីលេខ ១២ ក្រVII (ធ) ចុះថ្ងៃទី ២៧-មេសា-២០១៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ។

**៥**-ដើមចោទបានទាមទារ អោយសហចុងចម្លើយសងបំណុលមកខ្លួនមានដូចខាងក្រោម ៖

**ក**-ដើមចោទទាមទារប្រាក់ដើមនៅជំពាក់ចំនួន ៥៨,000 ដុល្លារអាមេរិក (ប្រាំម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) និង មាសចំនួន ៣៨តំឡឹង (សាបសិបប្រាំបីតំឡឹង) ការទាមទារនេះ សហចុងចម្លើយបានធ្វើការបញ្ជាក់ដូចខាងក្រោម ៖

-លោកស្រីមេធាវីតំណាងដោយ អាណត្តិអោយចុងចម្លើយឈ្មោះ [redacted] គីមអាត បានទទួលស្គាល់ថា កូនក្តីរបស់ខ្លួនពិតជាបានខ្ចីប្រាក់ និង មាស ដូចការទាមទាររបស់ដើមចោទពិតមែន ។

-មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយ និង ចុងចម្លើយឈ្មោះ [redacted] ហ៊ុយ ឬ [redacted] សុខឃឿន បានធ្វើការបញ្ជាក់ថា ខ្លួនពិតជាបានខ្ចីប្រាក់ និង មាស ពីដើមចោទ កាលពីពួកខ្លួននៅរួមរស់ជាមួយគ្នា ពិតមែន តែក្រោយមកខ្លួនបានសងប្រាក់ និង មាស នេះឱ្យទៅដើមចោទរួចហើយ ។

តាមការទាមទាររបស់ដើមចោទ ពីសហចុងចម្លើយទាំងពីរនាក់នេះគឺជាបំណុលដែលសហចុងចម្លើយបានខ្ចីពីខ្លួនតាំងចុងចម្លើយទាំងពីរនាក់នៅរួមរស់ជាមួយគ្នាជាប្តី ប្រពន្ធនឹងគ្នាមកម្លេះ ដោយចុងចម្លើយម្ខាងឈ្មោះ [redacted] គីមអាត បានទទួលស្គាល់តាមការទាមរបស់ដើមចោទ ឯចុងចម្លើយម្ខាងទៀតឈ្មោះ [redacted] ហ៊ុយ បាន បដិសេធមិនទទួលស្គាល់តាមការទាមទាររបស់ដើមចោទ ។ ប៉ុន្តែចុងចម្លើយឈ្មោះ [redacted] ហ៊ុយ មិនមានភស្តុតាងណាមួយជាក់លាក់មកបង្ហាញជូនតុលាការ ដើម្បីធ្វើការពិនិត្យ និង ពិចារណាឡើយ ដូច្នេះគប្បីតុលាការទទួលស្គាល់តាមការទាមទាររបស់ដើមចោទ ដោយហេតុថា ភស្តុតាងដែលដើមចោទបានដាក់ជូនតុលាការពិនិត្យ និង ការទទួលស្គាល់របស់ចុងចម្លើយឈ្មោះ [redacted] គីមអាត អាចឱ្យតុលាការជឿជាក់ និង មានទំនុកចិត្តថា ពិតជាមានការខ្ចីប្រាក់ និង មាស ដើមចោទ ដូចការទាមទារ ពិតប្រាកដមែន ។

**ខ**-ការទាមទារការប្រាក់ចំនួន ១ ភាគរយក្នុងមួយខែ លើប្រាក់ដើមដែលចុងចម្លើយខកខានបង់ចាប់ពីខែកក្កដា ឆ្នាំ ២០១៦ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន ការទាមទារនេះ តុលាការនឹងទទួលមកពិចារណាតាមច្បាប់ ។

យោងតាមប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកំរិត ចុះថ្ងៃទី ២១-ធ្នូ-២០១១ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រការ១ ចែងថា អត្រាការប្រាក់ដែលត្រូវបានកំរិតដែលកំណត់ក្នុងកថា ខណ្ឌទី១ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវបានកំរិតជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនអោយលើសពី ១៨ភាគរយ ក្នុងមួយឆ្នាំ ។

**គ**-សុំសាលក្រមអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើម ការប្រាក់ និង ការចំណាយផ្សេងៗ ការស្នើសុំលើចំណុចការប្រាក់ និង ការចំណាយផ្សេងៗ តុលាការមិនទទួលមកពិចារណាឡើយ ចំណែកប្រាក់ដើម តុលាការនឹងទទួលមកពិចារណា ដោយហេតុថាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] គីមអាត បានទទួលស្គាល់ថាកូនក្តីរបស់ខ្លួនពិតជាបានជំពាក់ប្រាក់ដូចការទាមទាររបស់ដើមចោទ ពិតមែន ។

**ឃ**-សេវាចំណាយផ្សេងៗ និង ការខាតបង់ពេលវេលា ចំនួន ២៥.០០០ដុល្លារអាមេរិក (ពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ចំណុចនេះ គប្បីតុលាការនឹងពិចារណាតាមស្ថានភាពជាក់ស្តែង ។

**ង**-ប្រាក់ប្រដាប់ក្តីសុំអោយសហចុងចម្លើយជាអ្នកទទួលបន្ទុក តុលាការនឹងទទួលមកពិចារណា ដោយយោងតាមមាត្រា ៦៤ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី ភាគីដែលចាញ់ក្តីត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

**៦**-តាមការអះអាងរបស់គូភាគី និង តាមឯកសារក្នុងសំណុំរឿង បញ្ជាក់ឱ្យឃើញថាភាគីសហចុងចម្លើយពិតជាបានខ្ចីប្រាក់ និង មាស ពីដើមចោទកាលនៅរួមរស់ជាមួយគ្នាជាប្តី ប្រពន្ធ ពិតមែន ដូច្នេះ គូភាគីពិតជាមានបំណុលរួមគ្នាហើយគូភាគីត្រូវរួមគ្នាសងនូវបំណុលនេះ ។

## **សេចក្តីសម្រេចបញ្ចប់**

**១**-ទទួលស្គាល់ការទាមទាររបស់ដើមចោទឈ្មោះ [redacted] **គីមធី** ភេទស្រី ដោយបង្គាប់ឱ្យសហចុងចម្លើយទាំងពីរនាក់ឈ្មោះ

**-**[redacted] **គីមអាត ឬ** [redacted] **គីមអាត** ភេទស្រី អាយុ៤៦ឆ្នាំ ។

**-**[redacted] **ហ៊ុយ ឬ** [redacted] **សុខឃឿន** ភេទប្រុស អាយុ៥១ឆ្នាំ ។

**រួមគ្នាបំពេញកាតព្វកិច្ចសងបំណុលឱ្យដើមចោទដូចខាងក្រោម :**

**ក**-សងប្រាក់ដើមចំនួន ៥៨,000 ដុល្លារអាមេរិក (ប្រាំម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) និង មាសចំនួន ៣៨តំឡឹង (សាបសិបប្រាំបីតំឡឹង)។

**ខ**-បង់ការប្រាក់ចំនួន ១២ ភាគរយក្នុង១ឆ្នាំ គិតពីថ្ងៃខកខានបង់ចាប់ពីខែ កក្កដា ឆ្នាំ ២០១៦ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន ។



Scanned with CamScanner

**គ**–បង់ប្រាក់សោហ៊ុយចំណាយផ្សេងៗ ចំនួន ៤0.000.000រៀល (សែសិបលានរៀល )

សំណូមពរទាមទារ លើសពីនេះ ត្រូវច្រានចោល ។

**២**–សាលក្រមនេះ អាចអនុវត្តបណ្តោះអាសន្នបាននូវចំណុចទី ១–ក ។

**៣**–ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

**សាលក្រមនេះទាញហេតុផលដោយផ្ទាល់មាត់ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ ចំពោះមុខមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] គឹមអាត និង កំបាំងមុខចុងចម្លើយឈ្មោះ [redacted] ហើយ ទុកសិទ្ធិឱ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។**

**ចៅក្រមទទួលបន្ទុក**

**ហត្ថលេខា និង ត្រា** [redacted]

---

**អនុសារសាលក្រមនេះ បានចម្លងត្រឹមត្រូវតាមលិខិត**

**សាលក្រមដើម ដើម្បីឱ្យទៅគូភាគី**

**ថ្ងៃព្រហស្បតិ៍ ១២រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤**

**កំពង់ធំ. ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០**

**បានឃើញ**

**ចៅក្រមទទួលបន្ទុក**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner